ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានពន្ធដារ

នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ......១១៥៩......អពដ

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១២

# សេចក្តីជូនដំណឹង

## ស្តីពី

## ការលក់លតាបត្រពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ចំពោះទោចក្រយានយន្ត និងត្រីចក្រយានយន្ត

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់អស់លោក-លោកស្រី ជាម្ចាស់ទោចក្រយានយន្ត និងត្រីចក្រយានយន្តទាំងអស់ឱ្យបានជ្រាបថា អគ្គនាយកដ្ឋានពន្ធដារបានសហការជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី ដើម្បីឱ្យធនាគារនេះទទួលផ្តល់សេវាកម្មលក់លតាបត្រពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ចំពោះទោចក្រយានយន្ត និងត្រីចក្រយានយន្ត ។ ការប្រមូលពន្ធនេះបានចប់ដោយបរិបូណ៌ត្រឹមថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១២ ប៉ុន្តែដើម្បីសម្រួលការបង់ពន្ធនេះសម្រាប់ទោចក្រយានយន្ត និងត្រីចក្រយានយន្តមួយចំនួនដែលទើបតែដាក់ឱ្យចរាចរ អគ្គនាយកដ្ឋានពន្ធដារ បានសម្រេចផ្តល់សិទ្ធិជូនធនាគារ អេស៊ីលីដា ភីអិលស៊ី សាកល្បងធ្វើសេវាកម្មលក់លតាបត្រពន្ធនេះ ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១២ និងត្រៀមការអនុវត្តដ៏ពេញលេញចាប់ពីដើមឆ្នាំ២០១៣ តទៅ ។

ចំពោះទោចក្រយានយន្តនិងត្រីចក្រយានយន្តទាំងឡាយណាដែលពុំមានបិទលតាបត្រពន្ធក្នុងអំឡុងពេលត្រួតពិនិត្យត្រូវបានកំណត់ ដូចខាងក្រោម ៖

- ទោចក្រយានយន្ត និងត្រីចក្រយានយន្ត ដែលមិនបានមកបង់ពន្ធត្រឹមកាលបរិច្ឆេទកំណត់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១២ ត្រូវទទួលការផាកពិន័យស្មើ១០០ភាគរយបន្ថែមលើប្រាក់ពន្ធដែលត្រូវបង់ និងតម្រូវឱ្យទៅទិញលតាបត្រពន្ធនៅធនាគារ អេស៊ីលីដា ភីអិលស៊ី ។
- ទោចក្រយានយន្ត និងត្រីចក្រយានយន្ត ដែលទើបតែដាក់ឱ្យចរាចរក្រោយថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១២ ត្រូវអនុគ្រោះឱ្យបង់ពន្ធក្នុងរយៈពេល ១ខែ គិតចាប់ពីថ្ងៃដែលដាក់ឲ្យធ្វើចរាចរ ដូចមានចែងក្នុងបណ្ណសម្គាល់យានយន្ត ។ បើពុំមកប្រកាសសុំបង់ពន្ធក្នុងរយៈពេលកំណត់ខាងលើ ភ្នាក់ងារពន្ធដារនឹងផាកពិន័យស្មើ១០០ភាគរយបន្ថែមលើប្រាក់ពន្ធដែលត្រូវបង់ និងតម្រូវឲ្យទៅទិញលតាបត្រពន្ធនៅធនាគារ អេស៊ីលីដា ភីអិលស៊ី ។

ដូចនេះ លោក-លោកស្រីដែលជាម្ចាស់ទោចក្រយានយន្ត និងត្រីចក្រយានយន្ត ដែលទើបតែដាក់ឱ្យចរាចរ និងពុំទាន់បានបង់ពន្ធនេះ មេត្តារួសរាន់ស្វែងរកទិញលតាបត្រអំពីពន្ធនេះនៅគ្រប់បញ្ជរបេឡាធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលមាននៅការិយាល័យកណ្តាល ការិយាល័យសាខាខេត្ត-ខណ្ឌ ការិយាល័យក្រុង-ស្រុក និងប៉ុស្តិ៍សេវាកម្មឃុំ-សង្កាត់ ដែលមានទីតាំងស្ថិតនៅជិតលោកអ្នក ។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមយ៉ាងមុតមាំថា លោក-លោកស្រី ជាម្ចាស់ទោចក្រយានយន្ត និងត្រីចក្រយានយន្តទាំងអស់ មានស្មារតីគោរពច្បាប់ និងបំពេញកាតព្វកិច្ចបានល្អប្រសើរ ជាពុំខាន ។

អគ្គនាយកដ្ឋានពន្ធដារ

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ២៣ ៨៨៦ ៧០៨/ ទូរសារ: (៨៥៥) ២៣ ៨៨៦ ៧០០

CORNER RUSSIAN FEDERATION & MAO TSETONG BLVD. TOEK LAAK 1, TOUL KAUK, PHNOM PENH Phone: (855) 23 886 708/ Fax: (885) 23 886 700